# អ្នកតា ម៉ឺន-គង់

ប្រជុំរឿងព្រេងខ្មែរភាគ ៨ ពីទំព័រទី ២៥ – ២៨

ប្រវត្តិអ្នកតា ម៉ឺន-គង់

---

១. "អ្នកតាដែលនៅលើខ្នងភ្នំធំ នៅឃុំត្រពាំងរាំង ស្រុកឈូក ខែត្រកំពត ឈ្មោះលោកតា ម៉ឺន-គង់ ។ មានរឿងដំណាលថា លោកតា ម៉ឺន-គង់ នេះ មានឥទ្ធិពលខ្លាំងក្លា មានអំណាចអស្ចារ្យជាងគេទាំងអស់ ពលរដ្ឋទាំងប្រុស- ស្រីក្នុងស្រុកឈូកទាំងមូល តែងតែគោរពកោតខ្លាចអំណាចលោកតា ម៉ឺន-គង់ នេះគ្រប់ៗគ្នា : អ្នកស្រុកទៅរកស៊ីឯព្រៃភ្នំម្ដងៗ ប្រយ័ត្នជានិច្ច ខ្លាចក្រែងនិយាយលេងហួសខុសមាត់ ពុំហ៊ាននិយាយចម្អេះចំអាសសើចលេងទេ ។ មានរឿងរ៉ាវជាច្រើនតាមពួចាស់ៗដំណាលតៗ គ្នាមកថា : កាលជំនាន់ជាង ១០០ ឆ្នាំប្លាយមកហើយពលរដ្ឋក្នុងស្រុកឈូកនេះ ពុំសូវហ៊ានទៅរកនៅឯព្រៃនោះទេ ដោយលោកតា គង់ នេះកំពុងមានឥទ្ធិពលអស្ចារ្យណាស់ អ្នកស្រុកដាំបាយពុំហ៊ានយកវែកគងលើមាត់ឆ្នាំងទេ ពុំហ៊ានលូកបាយបរិភោគក្នុងឆ្នាំងទេ ពុំហ៊ានដេកគងអន្ទាក់ទេ ពុំហ៊ានថាអញគ្មានខ្លាចអ្វីក្នុងព្រៃនេះទេ និងពុំហ៊ាននិយាយចំអែចំអន់សើចលេងដូចជានៅផ្ទះនោះផង ដោយខ្លាចខុសមាត់ ។ បើមានឈ្មោះណាខុសមាត់ ឬខុសដោយប្រការណាមួយ ពេលដើរទៅ នឹងឃើញពស់វែករនាមធំៗ ឬយប់ឡើង នឹងឃើញខ្លាធំៗ មកយំគគ្រឹកគគ្រេងដេកពុំបានទេ បើមានចាស់គេដឹងថាខុសមាត់ គេនិយាយបន់ថា "លោកតា ម៉ឺន-គង់ អើយ ខ្ញុំខ្មាសអៀនណាស់ សុំហៅគោលោកតាទៅវិញទៅ ខ្ញុំរាងចាលហើយ" ថាតែប៉ុណ្ណោះ គឺស្រាប់តែបាត់ភ្លាមទៅវិញ ពួតា ដួង និយាយថា "មានមនុស្សបីនាក់ទៅរកស៊ីឯព្រៃភ្នំ មានម្នាក់ខុសមាត់ ហើយដេកលើខ្នមកណ្ដាលគេទៀត ស្រាប់តែខ្លាលបខាំ ពាំយកអ្នកខុសមាត់ទៅបាត់ អ្នកដេកជាមួយគ្នាភ្ញាក់ឡើង ឃើញតែដានខ្លារកមនុស្សពុំឃើញក៏សឹងមាន ។ ពួចាស់និយាយថា តាប៉ែននិងតាទូច ទៅរកស៊ីឯខាងលិចភ្នំធំ ជិតផ្ទះដែរ ហើយខ្លាវាដើរតាមពីភ្នំធំមកដេញខាំតាប៉ែនៗ រត់ឡើងដើមឈើមួយដើម ខ្លាវាឡើងតាមខាំតាប៉ែនយកទៅស៊ីអស់សាច់ពាក់កណ្ដាលស្លាប់ទៅ ឯតាទូចគ្មានខុសមាត់នោះត្រឡប់មកផ្ទះឥតមានខ្លាតាមទេ តាទូចប្រាប់កូនតាប៉ែន កូនតាប៉ែនទៅតាមរក ឃើញស្នាមខ្លាស៊ីដល់ស្លាប់មែន ជាប់ពាក្យដល់សព្វថ្ងៃនេះថា ដើមឈើធំនៅឯទួលខ្លាខាំប៉ែន" ។

២. កាលជំនាន់ជិត ១០០ ឆ្នាំមុន មានឈ្មោះតាឡុច គាត់ទៅកាប់ឈើ ដេកឯព្រៃនៅជើងភ្នំធំ គ្នាគាត់ទាំងអស់ប្រាំមួយនាក់ ឈ្មោះតាហ៊ុក ១ តាទូច ១ តាញេប ១ តាតុប ១ តាដួង ១ ដេកយប់នោះទៅ ឮភ្លេងភ្លេងសៀមលេងរាំនៅក្បែរជើងភ្នំដែលមានប្រហោង ។ តាឡុចថាថ្លង់ដេកពុំបាន ក៏ទៅចុកប្រហោងនោះ ចុកទៅនៅតែឮ តាប្រាំនាក់ទៀតឃាត់ពុំស្ដាប់ ទៅនោមច្រាសប្រហោងភ្នំនោះទៀត ស្រាប់តែមកដល់ផ្ទះវិញ ចាប់ឈឺជាទម្ងន់ ទៅជាថ្លង់ស្ដាប់អ្វីៗពុំឮ ខ្វាក់ភ្នែកទាំងពីរទៀត ហើយដំបៅលិង្គរលួយទាល់តែស្លាប់ទៅ ។ ឯអ្នកប្រាំនាក់ទៀតនោះ គ្មានគ្រោះថ្នាក់ទេ ទើបពួតៗមកថា

លោកតា ម៉ឺន-គង់ នេះខ្លាំងពូកែហើយកាចណាស់ ក៏នាំគ្នាខ្លាចរហូតមកដល់សព្វថ្ងៃ ។ ឯភ្នំធំនោះមានប្រហោងឬរូងជ្រៅណាស់ ពុំដឹងជាទៅដល់ណាទេ ។ កាលនោះកូនតាដួង គាត់ចង់ឃើញពស់វែករនាម តាដួង ក៏នាំកូនទៅនៅមុខរូងនោះ បន្តិចស្រាប់តែឮសូរវ៉ូៗ កូនគាត់ក្រឡេកទៅ ឃើញពស់ភ័យញ័ររន្ធត់ តាដួងក៏បន់ថា លោកតាម៉ឺន-គង់អើយ កូនចៅខ្លាចអៀនណាស់ សុំលែងឲ្យឃើញចុះ ពស់នោះក៏លូនចូលបាត់វិញទៅ ។ ក្នុងជំនាន់នោះ តែដល់ថ្ងៃសីលអ្នកស្រុកវត្តចក តែតែឮភ្លេងសៀម និងឃើញភ្លើងគោមភ្លឺដូចម៉ាំងសុង នៅលើកំពូលភ្នំធំនោះជានិច្ច ។

៣. អំពីឡើងអ្នកតា កាលបើមានអ្នកស្រុកឈឺក្ដៅអន្ទះអន្ទែង សន្លប់បាត់មាត់ ឬនិយាយរវើរវាយ ពុំដឹងខុសត្រូវនោះ គេច្រើនទៅបញ្ចូលរូបលោក ញឹម នៅភូមិតាឥន្ទ ឃុំត្រពាំងរាំង សុំឲ្យជួយមើលជំងឺ ហើយអង្វរករថា ធ្វើម្ដេចកូនចៅបានជាខុសឆ្គងម្ដងម្កាល សូមលោកតាកុំចាប់ទោសអូសដំណើរអីហើយបន់ថ្វាយភ្លេង រៀបចំស្លកប្រាំបី ឬកាប់មាន់ទា ជ្រូកថ្វាយក៏មាន រៀបចំនៅផ្ទះអ្នកជំងឺនោះ ។ លោកតា ម៉ឺន-គង នេះគ្មានរូបដុំថ្មជាតំណាងទេ គឺនៅលើភ្នំធំតែម្ដង មានតែរូបមនុស្សប្រុសឈ្មោះ ព្រំ-ញឹម អាយុ៧៥ ឆ្នាំ ជារូបសំណឹងរបស់អ្នកតា សព្វថ្ងៃនេះមុនតាញឹម មានឈ្មោះតា ព្រំ ជាឪពុកតាញឹម ធ្វើជារូបអ្នកតា លុះតាព្រំស្លាប់ទៅ អ្នកតានោះមកចូលតាញឹម ជាកូនតាព្រំ គ្មានពិធីត្រូវធ្វើប្រចាំឆ្នាំចំពោះលោកតា ម៉ឺន-គង់នេះទេ ទាល់តែមានមនុស្សឈឺទើបគេទៅយករូប ព្រំ-ញឹម មកបញ្ចាន់មើល និងលេងភ្លេងថ្វាយតាមរបៀបដូចខាងលើនេះ ។

៤. ឥទ្ធិពលព្រៃភ្នំធំនេះ សាបរលាបឥទ្ធិពលខ្លះៗ ទៅហើយ អ្នកស្រុកជាច្រើនទៅរកស៊ី ពុំឃើញមានគ្រោះថ្នាក់អ្វីទេ តែអ្នកស្រុកនៅតែជឿខ្លាំងដោយសារខ្លាចតៗគ្នា មកទល់សព្វថ្ងៃនេះ អ្នករាជការធំៗពុំជឿទេ ទាល់តែអ្នកស្រុកភូមិធ្លាប់ទៅរកស៊ីឯព្រៃធំ ទើបជឿឥទ្ធិពលលោកតា ម៉ឺន-គង់ ។